# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជានៅគងនយ
# ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៧

អត្ថបទទី១៖ អស ៥,១-៧
អត្ថបទទី២៖ ភីល ៤,៦-៩
ដំណឹងល្អ៖ មថ ២១,៣៣-៤៣

បងប្អូនជាទីស្រឡាញ់!

អត្ថបទទីមួយ យើងឃើញមានម្ចាស់ចម្ការ គាត់ខិតខំរៀបចំចម្ការគាត់យ៉ាងល្អ គាត់ភ្ជួរដីដាក់ជី ស្រោចទឹក និងគាត់មានសង្ឃឹមមែនទែន។ ឆ្នាំនេះគាត់ខិតខំធ្វើចម្ការគាត់ បានផ្លែច្រើនណាស់ ប៉ុន្តែគាត់ភ្ញាក់នៅពេលដែលដល់វេលាដែលគាត់ត្រូវច្រូត គាត់ឃើញអត់មានផ្លែល្អសោះ ចម្ការរបស់គាត់ដែលគាត់យកចិត្តទុកដាក់ថែរក្សាអស់ពីសមត្ថភាព ដោយសេចក្តីសង្ឃឹមរបស់គាត់ផ្លែច្រើនណាស់ តែអត់មានអីសោះ។ ប្រហែលអ្នកដែលធ្វើស្រែនៅទីនេះ ក៏មានបទពិសោធន៍ដែរ ជួនកាលយើងយកចិត្តទុកដាក់ធ្វើ ប៉ុន្តែដោយសារទឹកភ្លៀងច្រើនពេក ឬខ្វះទឹកភ្លៀង ឬមានសត្វល្អិតដែលមកស៊ីអស់ហើយ នៅពេលច្រូត យើងអត់មានអីសោះ។ ព្រះជាម្ចាស់និយាយដូចនេះដើម្បីឲ្យយើងគិតដែរ **ព្រះជាម្ចាស់មានសេចក្តីសង្ឃឹមលើយើងទាំងអស់ ព្រះជាម្ចាស់សង្ឃឹមថាមនុស្សយើងជាមនុស្សល្អ មនុស្សយើងជាមនុស្សសុចរិត មនុស្សយើងជាមនុស្សដែលសុទ្ធតែប្រព្រឹត្តអំពើល្អដល់អ្នកដទៃ** នេះជាសេចក្តីសង្ឃឹមរបស់ព្រះជាម្ចាស់សម្រាប់យើងទាំងអស់ ប៉ុន្តែច្រើនដងព្រះជាម្ចាស់ដូចជាពិបាកចិត្ត ដោយសារព្រះអង្គឃើញយើងប្រព្រឹត្តខុស ប្រព្រឹត្តអត់ល្អ យើងធ្វើអំពើដែលណែនាំឲ្យបងប្អូនឯទៀតៗពិបាកចិត្ត យើងណែនាំឲ្យអ្នកដទៃអស់សង្ឃឹមដោយសារយើងណែនាំឲ្យព្រះជាម្ចាស់ឈឺចិត្តដែរ។ ដូច្នេះ ថ្ងៃនេះដែលយើងគោរពខួប១០ឆ្នាំនៃព្រះសហគមន៍គងនយ សម្រាប់បងប្អូននៅទីនេះសុទ្ធតែអ្នកថ្មីៗ។ ប៉ុន្តែ អ្វីដែលសំខាន់ឲ្យយើងគិតអំពីអនាគតយើង និងឲ្យយើងទទួលយកព្រះបន្ទូលព្រះយេស៊ូនៅក្នុងថ្ងៃនេះ **យើងធ្វើយ៉ាងមិចដើម្បីទៅជាមនុស្សល្អ** នេះជាអ្វីដែលព្រះយេស៊ូទន្ទឹងរង់ចាំពីយើង ព្រះយេស៊ូចង់ឲ្យជីវិតរបស់យើងទៅជាជីវិតល្អពិសេស។

ចាប់ពីពេលនេះតទៅ យើងធ្វើយ៉ាងមិចឲ្យជីវិតរបស់យើងទៅជាជីវិតមួយយ៉ាងពិសេសដើម្បីណែនាំ ដើម្បីឲ្យព្រះជាម្ចាស់សប្បាយចិត្ត ដើម្បីណែនាំឲ្យបងប្អូនឯទៀតៗមានសេចក្តីសុខ។ នៅក្នុងអត្ថបទទី២ យើងបានស្តាប់ថា **ព្រះជាម្ចាស់ចង់ណែនាំឲ្យយើងមានសេចក្តីសុខសាន្ត** សម្រាប់យុវជន យុវនារី សម្រាប់តាយាយ ពូ មីង សេចក្តីសុខសាន្តសំខាន់ណាស់ សេចក្តីសុខសាន្តនៅក្នុងចិត្ត សេចក្តីសុខសាន្តនៅក្នុងជីវិត សេចក្តីសុខសាន្តនៅក្នុងការងារ សេចក្តីសុខសាន្តនៅក្នុងប្រទេសយើង។ ថ្ងៃនេះនៅមណ្ឌលភ្នំពេញថ្មីយើងមានទិវាពលករ ពលករពេលគេធ្វើការនៅរោងចក្រ ជួនកាលគេខ្វះសេចក្តីសុខសាន្តដែរ ដោយសារត្រូវគោរពច្បាប់ការងារ ដោយសារម៉ោងច្រើន

ដោយសាររឿងច្រើនដែលកើតឡើង។ សម្រាប់សិស្សសាលាក៏ដូចគ្នាដែរ ប៉ុន្មានដងដែលខ្វះសេចក្តីសុខសាន្ត ដោយសារយើងត្រូវបង់លុយគួតែយើងអត់មានលុយ ដោយសារយើងរៀនអត់ទាន់ ដោយសារនៅផ្ទះយើងអត់មានកន្លែងដើម្បីរៀនសូត្រ សម្រាប់ពូ មីង ក៏សេចក្តីសុខសាន្តជួនកាលខ្វះដែរ ដោយសារម្ហូបអាហារមិនគ្រប់គ្រាន់ ដោយសារមានជម្ងឺ ដោយសារកូនយើងដើរលេងច្រើនពេក មានរឿងច្រើនដែលណែនាំឲ្យយើងខ្វះសេចក្តីសុខសាន្ត។ លោកប៉ូល គាត់ថា **សេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ ដែលហួសពីការស្មានរបស់មនុស្សនឹងស្ថិតជាប់នៅក្នុងចិត្តគំនិតរបស់បងប្អូន ប្រសិនបើយើងយកចិត្តទុកដាក់គិតតែពីអ្វីៗដែលពិតថ្លៃថ្នូរ ប្រសិនបើយើងសុចរិតបរិសុទ្ធ គួរឲ្យស្រឡាញ់ គួរឲ្យគោរព និងគំនិតណាដែលល្អឥតខ្ចោះ គួរឲ្យកោតសរសើរ។** ប្រសិនបើយើងជាមនុស្សដែលគិតតែពីអំពើល្អ ប្រសិនបើយើងជាមនុស្សដែលគិតតែយកចិត្តទុកដាក់ប្រព្រឹត្តអំពើល្អដល់បងប្អូនឯទៀតៗ នេះជាអ្វីដែលព្រះយេស៊ូបានសុំពីយើង ប្រសិនបើយើងនឹកឃើញដល់ព្រះសហគមន៍របស់យើងតាំងពី១០ឆ្នាំកន្លងមក យើងបានធ្វើអ្វីខ្លះសម្រាប់អ្នកដទៃ តាមគណៈកម្មាការសង្គហៈ បានជួយអង្ករ ជួយអ្នកក្រីក្រ យើងបានជួយអ្នកជម្ងឺឲ្យព្យាបាល សព្វថ្ងៃយើងមានសាលាមត្តេយ្យ យើងមានក្រុមយុវជនដែលណែនាំឲ្យមានសេចក្តីសុខ យើងធ្វើយ៉ាងមិចដើម្បីឲ្យព្រះសហគមន៍របស់យើង ទៅជាសញ្ញាសម្គាល់នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់? សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ ត្រូវតែដឹកនាំជីវិតរបស់យើងដោយយកចិត្តទុកដាក់ ដូចសន្តប៉ូលបាននិយាយ ធ្វើអំពើល្អ យកចិត្តទុកដាក់ទៅជាមនុស្សសុចរិត មនុស្សបរិសុទ្ធ មនុស្សដែលគួរឲ្យគេស្រឡាញ់និងគោរព។ ដូច្នេះ សម្រាប់យើងទាំងអស់ដែលយើងមានអាយុតិចក៏ដោយ យើងមានអាយុច្រើនក៏ដោយ ថ្ងៃនេះព្រះជាម្ចាស់អញ្ជើញយើងឲ្យយើងចែករំលែកសេចក្តីសុខសាន្តតទៅទៀត។ ដើម្បីចែករំលែកសេចក្តីសុខសាន្ត យើងធ្វើយ៉ាងមិចដើម្បីទៅជាមនុស្សដែលចេះស្រឡាញ់គេ ចេះគោរពគេ ចេះលើកលែងទោសឲ្យគេ នេះជាអ្វីដែលព្រះយេស៊ូបានបង្រៀនយើង។ ដូច្នេះព្រះសហគមន៍របស់យើងទៅជាព្រះសហគមន៍របស់ព្រះយេស៊ូ ប្រសិនបើយើងចេះបង្ហាញពន្លឺរបស់ព្រះគ្រីស្តលោកប៉ូលបាននិយាយថា "**សេចក្តីដែលបងប្អូនបានរៀន បានទទួល និងបានឮពីខ្ញុំ ហេតុការអ្វីដែលបងប្អូនបានឃើញខ្ញុំធ្វើនោះ ចូលបងប្អូនប្រព្រឹត្តតាមទៅ**" មានន័យថាលោកប៉ូលជាគំរូ លោកប៉ូលគាត់ប្រកាសពីព្រះយេស៊ូ។ លោកប៉ូលគាត់ខិតខំស្រលាញ់គ្រីស្តបរិស័ទថ្មីៗ លោកប៉ូលគាត់ខិតខំធ្វើដំណើរពីភូមិមួយទៅភូមិមួយដើម្បីប្រកាសដំណឹងល្អ អ្វីៗទាំងអស់ដែលគាត់និយាយ អ្វីទាំងអស់ដែលគាត់ប្រព្រឹត្ត កាយវិការរបស់គាត់ សំដីរបស់គាត់ ទៅជាគំរូរបស់យើង។ ដូច្នេះលោកប៉ូលគាត់ហ៊ាននិយាយថា "**ឥឡូវនេះមើលខ្ញុំទៅ និងធ្វើតាមខ្ញុំ**" សម្រាប់យើង តើបងប្អូនឯទៀតៗនៅពេលដែលគេមើលយើង ពេលគេឃើញយើង តើគេមានអារម្មណ៍ថាចង់ធ្វើតាមយើងឬអត់? យើងត្រូវការគិតដូចនេះ ទោះបីនៅសាលា នៅក្នុងគ្រួសារយើង ប្រសិនបើយើងជាអ្នកដែលចេះញញឹមទៅគេ

ជួយគេ លើកទឹកចិត្តគេ ប្រហែលគេយល់ថា គេចង់ធ្វើតាម ប្រសិនបើយើងចេះតែអត់ចាប់អារម្មណ៍អំពីគេ និងយើងចេះតែប្រព្រឹត្តតែអំពើខុសនឹងព្រះហឫទ័យព្រះជាម្ចាស់ ប្រហែលគេអត់មើលយើងទេ។

ដូច្នេះថ្ងៃនេះ យើងទទួលបេសកកម្មមួយយ៉ាងពិសេស **ធ្វើដូចម្ដេចដើម្បីឲ្យគេមើលយើង និងឲ្យគេធ្វើតាមយើង?** យើងត្រូវការគិតដូចនេះ ដើម្បីឲ្យយើងក្លាយទៅជាពន្លឺមួយដែលចេះញញឹមដល់គេ យើងចេះស្រឡាញ់គេ ពន្លឺមួយដែលណែនាំឲ្យគេទទួលជីវិតប្រកបដោយសេចក្ដីសុខសាន្ត។ ថ្ងៃនេះ ជាឱកាសមួយ ដើម្បីអរព្រះគុណព្រះជាម្ចាស់ និងរួមជាមួយលោកឪពុក រួមជាមួយបងប្អូនដែលមកទីនេះ ជាមួយគណៈកម្មាការដែលមកពីព្រះសហគមន៍នីមួយៗ។ យើងត្រូវតែបន្ដយកចិត្តទុកដាក់ ដើម្បីឲ្យព្រះសហគមន៍យើង ធ្វើយ៉ាងមិចឲ្យយើងទៅជាពន្លឺ ដោយបងប្អូនឯទៀតៗចង់ធ្វើតាមយើង ដោយសារគ្រីស្ដបរិស័ទនេះគេចេះស្រឡាញ់ ដោយសារគ្រីស្ដបរិស័ទគេយកចិត្តទុកដាក់ ដោយសារគ្រីស្ដបរិស័ទគេមានចិត្តអាណិតមេត្តា ដោយសារគ្រីស្ដបរិស័ទគេមិនចេះវិនិច្ឆ័យកាត់ក្ដី ដោយសារគ្រីស្ដបរិស័ទគេចេះទទួលស្វាគមន៍ជានិច្ច ដោយសារគ្រីស្ដបរិស័ទមានចិត្តទូលំទូលាយដែលយកចិត្តទុកដាក់នឹងមនុស្សទាំងឡាយ។ ប្រសិនបើ យើងអាចទៅជាគំរូសម្រាប់គេ យើងយល់ថា យើងធ្វើឲ្យព្រះជាម្ចាស់មានអំណរសប្បាយ កុំឲ្យព្រះជាម្ចាស់អស់សង្ឃឹមនឹងយើង។

យើងបន្ដយកចិត្តទុកដាក់ ដើម្បីឲ្យមានផ្លែល្អយ៉ាងច្រើន ដើម្បីឲ្យព្រះជាម្ចាស់ផ្ដល់កម្លាំងឲ្យយើងថែមទៀត និងណែនាំឲ្យបងប្អូនឯទៀតៗ អ្នកដែលអត់ទាន់ស្គាល់ព្រះសហគមន៍ អ្នកដែលគ្មានទីពឹង អ្នកដែលអស់សង្ឃឹមនៅក្នុងជីវិត អ្នកដែលអត់មានអ្នកណាដែលរវីរវល់នឹងគេសោះ អ្នកដែលនៅក្នុងសង្គមគេចេះតែមើលងាយ ឲ្យយល់ថានៅកន្លែងព្រះសហគមន៍កាតូលិក កន្លែងព្រះយេស៊ូ មានតែបងប្អូនដែលចេះស្វាគមន៍យ៉ាងរាក់ទាក់ និងស្រឡាញ់គេ។ សូមអរព្រះគុណព្រះជាម្ចាស់ និងសូមឲ្យព្រះអង្គប្រទានពរ និងឲ្យយើងបន្ដទៅជាមនុស្សល្អ ដោយប្រព្រឹត្តតែអំពើល្អ ដោយមានតែគំនិតល្អ គួរឲ្យស្រឡាញ់ គួរឲ្យគោរព ដូចសន្ដប៉ូល និងជាពិសេសដោយមើលព្រះយេស៊ូជានិច្ច ដោយសារ**ព្រះយេស៊ូជាជីវិត ជាផ្លូវ និងជាសេចក្ដីពិត** សម្រាប់យើងម្នាក់ៗ។ អាម៉ែន៕